


# គម្រោងអង្គការអន្តរជាតិខាងការងារ-ប្រទេសចិន ការពង្រឹងការអភិវឌ្ឍជំនាញក្នុងប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា តាមរយៈកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង និងត្រីភាគី

មិថុនា/២០២២

## ទិដ្ឋភាពទូទៅនៃគម្រោង

### ដៃគូ

- កម្ពុជា: ក្រសួងការងារ, សហព័ន្ធនិយោជក, និងសហជីព
- ឡាវ: ក្រសួងការងារ, សហព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម, និងសហជីពឡាវ
- មីយ៉ាន់ម៉ា: ក្រសួងការងារ, សហព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម, និងសហព័ន្ធសហជីពមីយ៉ាន់ម៉ា

### ផ្តល់មូលនិធិដោយ

ក្រសួងធនធានមនុស្ស និងសន្តិសុខសង្គម, ប្រទេសចិន

### រយៈពេល

ខែមករា ឆ្នាំ២០២០ - ខែធ្នូ ឆ្នាំ២០២៥

### ក្រុមអ្នកទទួលផលគោលដៅ

- ក្រុមទទួលផលផ្ទាល់៖ ក្រសួង/ភ្នាក់ងារ, ស្ថាប័ននយោជិក និងនយោជក ដែលធ្វើការលើកកម្ពស់ជំនាញ និងមុខរបរ
- ក្រុមទទួលផលចុងក្រោយ៖ អ្នកស្វែងរកការងារ, នយោជិក, នយោជក, អ្នកផ្តល់ការបណ្តុះបណ្តាល

### ប្រទេសគោលដៅ

កម្ពុជា, ឡាវ និងមីយ៉ាន់ម៉ា

## គោលបំណងនៃគម្រោង

គម្រោងនេះមានគោលបំណងលើកកម្ពស់ភាពមានការងារធ្វើរបស់នយោជិក និងបង្កើនផលិតភាពរបស់សហគ្រាស តាមរយៈភាពប្រសើរឡើងនៃសេវាមុខរបរ ការអភិវឌ្ឍជំនាញ និងការកសាងសមត្ថភាពស្ថាប័ន។

គម្រោងផ្តោតសំខាន់លើបីផ្នែក៖ ការផ្សារភ្ជាប់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅនឹងតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន ក៏ដូចជាការធ្វើការប៉ាន់ប្រមាណតម្រូវការជំនាញ, ការងារបៃតង, ការអភិវឌ្ឍស្តង់ដារសមត្ថភាព កម្មវិធីសិក្សា និងគុណវុឌ្ឍិ តាមរយៈការភ្ជាប់បណ្តាញ និងសម្ព័ន្ធភាពរវាងប្រទេសទទួលផល, ម្ចាស់ជំនួយ, រដ្ឋសមាជិកអាស៊ាន។ល។ លើកកម្ពស់ការចែករំលែកចំណេះដឹងស្តីពីការអភិវឌ្ឍជំនាញ សេវាការងារសាធារណៈ ការងារបៃតង តាមរយៈកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង និងត្រីកោណ។

គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីកែលម្អការអភិវឌ្ឍជំនាញ, ការចូលរួមក្នុងទីផ្សារការងារ, លើកកម្ពស់សមភាពយេនឌ័រ និងបរិយាប័ន្ន ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ សាកលភាវូបនីយកម្ម និងវឌ្ឍនភាពនៃបច្ចេកវិទ្យាធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សចំពោះតម្រូវការជំនាញរបស់សហគ្រាស ហើយបានដាក់សម្ពាធលើសហគ្រាសទាំងនោះក្នុងការស្វែងរកនយោជិកដែលមានសមត្ថភាព និងកម្លាំងពលកម្មក្នុងការស្វែងការងារធ្វើ។ ការកែលម្អគុណភាពនៃសេវាការងារតាមរយៈការពង្រឹងការតម្រង់ទិសអតិថិជន និងការកសាងសមត្ថភាពរបស់មជ្ឈមណ្ឌលការងារ និងមន្ត្រីរបស់ពួកគេ ព្រមទាំងការកែលម្អគុណភាព និងការវិភាគព័ត៌មានទីផ្សារការងារ គឺជាសមាសធាតុដ៏សំខាន់ក្នុងគម្រោងនេះ។ វិធីសាស្ត្រ និងឧបករណ៍សមស្របសម្រាប់ការកសាងសមត្ថភាពនឹងត្រូវបានបង្កើតឡើងជាមួយដៃគូត្រីភាគី។

គម្រោងនេះនឹងអនុវត្តក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង និងត្រីកោណ។ ការគាំទ្រពីប្រទេសចិននឹងរួមបញ្ចូលទាំងផ្នែកហិរញ្ញវត្ថុ និងការផ្លាស់ប្តូរចំណេះដឹង ផ្អែកតាមបទពិសោធន៍ទាំងកម្រិតជាតិ និងអន្តរជាតិ។ ជាតុស្នូលនៃកិច្ចសហប្រតិបត្តិការនេះគឺជំនួយបច្ចេកទេស ការផ្តល់ប្រឹក្សា និងការចែករំលែកការអនុវត្តល្អៗ។ ជាមួយនឹងជំនាញរបស់អង្គការអន្តរជាតិខាងការងារ និងករណីសិក្សាជាក់ស្តែងជាច្រើនពីតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់ដ៏ទៃទៀត គម្រោងមានបំណងរួមចំណែកឲ្យកាន់តែមានការអភិវឌ្ឍជំនាញ និងទីផ្សារការងារបន្ថែមទៀតដើម្បីចូលរួមជម្រុញកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម ព្រមទាំងឈានទៅមុខជាមួយការងារបច្ចុប្បន្ន ក្រោមរបៀបវារៈសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន។



## ទិន្នផលគម្រោង

បង្កើនគុណភាពនៃការបណ្តុះបណ្តាលជំនាញ និងសេវាកម្មការងារដែលផ្តល់ដោយក្រសួង/ទីភ្នាក់ងារដែលទទួលខុសត្រូវ និងពង្រឹងការតម្រង់ទិសអតិថិជននៃបណ្តាញស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលការងារ។

- ការអភិវឌ្ឍស្តង់ដារសមត្ថភាព និងគុណវុឌ្ឍិជំនាញ
  - ការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
  - បង្កើតបណ្តាញ/សម្ព័ន្ធស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ
  - លើកកម្ពស់ការយកចិត្តទុកដាក់លើជំនាញ និងការប្រកួតប្រជែងជំនាញនៅលើឆាកអាស៊ាន និងអន្តរជាតិ។
- ការអភិវឌ្ឍឧបករណ៍សេវាកាងារ ដើម្បីប្រើប្រាស់ក្នុងមជ្ឈមណ្ឌលការងារ ដូចជាការបណ្តុះបណ្តាលជំនាញកំព្យូទ័រ និងការគ្រប់គ្រងទិន្នន័យ។
- ការអភិវឌ្ឍកញ្ចប់ទំនាក់ទំនង សម្រាប់សាធារណៈជន ស្ថាប័ននយោជក និងសហជីព អំពីសេវាការងារ និងមជ្ឈមណ្ឌលការងារ។
- ការចងក្រងឯកសារ និងការចែករំលែកការអនុវត្តល្អៗ ដោយប្រើកិច្ចសហប្រតិបត្តិការកម្រិតស្មើគ្នា និងត្រីកោណជាមួយប្រទេសចិន និងប្រទេសជាសមាជិកនៃសហគមន៍អាស៊ាន។

## សកម្មភាពចម្បងៗ

ការអភិវឌ្ឍជំនាញ និងសេវាការងារដើរតួនាទីសំខាន់ក្នុងរបៀបវារៈការងារសមរម្យ។ យុទ្ធសាស្ត្រអភិវឌ្ឍរបស់គម្រោងមានពីរ ដែលផ្តោតលើសកម្មភាពដូចខាងក្រោម៖

- ការពង្រឹងការអភិវឌ្ឍជំនាញ និងការបង្កើតគោលនយោបាយសេវាការងារ រួមមានស្តង់ដារសមត្ថភាព និងគុណវុឌ្ឍិ, កម្មវិធីសេវាការងារសកម្ម ។ល។
- ការពង្រឹងការកសាងសមត្ថភាពស្ថាប័ន រួមមានសមត្ថភាពរបស់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រូឧទេសដើម្បីផ្តល់សេវាប្រកបដោយគុណភាព។ កែលម្អការប្រមូល ការវិភាគ និងការផ្សព្វផ្សាយព័ត៌មានទីផ្សារ ដើម្បីសេវាកម្មកាន់តែប្រសើរសម្រាប់អ្នកស្វែងរកការងារ និងសហគ្រាស ខណៈពេលដោះស្រាយតម្រូវការរបស់យុវជន ស្ត្រី ពលករចំណាកស្រុក និងជនមានពិការភាព។



▶ ទំនាក់ទំនងសម្រាប់ព័ត៌មានលម្អិត៖

លោក **លីវ យូតុខ**
ប្រធានគម្រោង និងអ្នកសម្របសម្រួល
គម្រោងអង្គការអន្តរជាតិខាងការងារ-ប្រទេសចិនស្តីពីការពង្រឹងការអភិវឌ្ឍជំនាញក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា តាមរយៈកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង និងត្រីកោណ

**ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក**
ទូរស័ព្ទ៖ +៦៦ ២២៨៨ ២១០៧
អ៊ីម៉ែល៖ liuyu@ilo.org
គេហទំព័រ៖ ilo.org/chinaprogramme